ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
តាងនាមប្រជារាស្ត្រខ្មែរ
តុលាការកំពូល

តុលាការកំពូល
សភាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខៈ ១០
ចុះថ្ងៃទី១១-០២-៩៨
សាលដីកាលេខ៖១០
ចុះថ្ងៃទី១៧-០៣-៩៩

បានបើកសវនាការជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១៧ ខែមីនា ឆ្នាំ ១៩៩៩ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជម្រះដូចតទៅ៖

១-ឯកឧត្តម ... ប្រធាន
២-លោក ... ចៅក្រម
៣-លោក ... ចៅក្រមរបាយការណ៍
៤-លោក ... ចៅក្រម
៥-លោក ... ចៅក្រម

ក្រឡាបញ្ជីលោក...

តំណាងមហាអយ្យការ ...ព្រះរាជអាជ្ញា

ដើម្បីជំនុំជម្រះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ១៧៥ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍និងសំណុំរឿងព្រហ្មទណ្ឌលេខ១០ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ១៩៩៨ របស់តុលាការកំពូល។

ពីបទ៖ ធ្វើមនុស្សឃាតដោយចេតនាប្រព្រឹត្តិនៅក្រុងភ្នំពេញកាលពីថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៩៤ បទល្មើសដែលមានចែងនិងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២។

-ជនជាប់ចោទឈ្មោះ **សឆ** ជាម្ចាស់បណ្តឹងសាទុក្ខ ភេទប្រុស អាយុ៤០ ឆ្នាំ ជាតិខ្មែរ កើតនៅឃុំព្រែកល្ពង ស្រុកខ្សាច់ ខេត្តកណ្តាល របររកស៊ីនគរបាល មានទីលំនៅសព្វថ្ងៃផ្ទះលេខ២៨០អឺ១ ក្រុម៣៥ សង្កាត់បឹងរាំងខណ្ឌដូនពេញ ក្រុងភ្នំពេញ ឪពុកឈ្មោះ...ម្តាយឈ្មោះ...ប្រពន្ធឈ្មោះ...មានកូន៣នាក់។

ក្រៅឃុំមានមេធាវីលោក..។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ **គដររ** ជាចុងបណ្តឹងសាទុក្ខ ភេទប្រុស ជាតិខ្មែរ របររកស៊ីមន្ត្រីរាជការ នៅវិទ្យាស្ថានស្រាវជ្រាវកៅស៊ូ មានទីលំនៅសព្វថ្ងៃផ្ទះលេខ១២២ អឺអូ មហាវិថីសីហនុ សង្កាត់បឹងកេងកងទី១ ខណ្ឌចំការមន ក្រុងភ្នំពេញ ។ មេធាវី គ្មាន។

-បណ្តឹងសាទុក្ខលេខ៣៤៥ ចុះថ្ងៃទី១៥ ខែកញ្ញាឆ្នាំ១៩៩៧ របស់ឈ្មោះ **សឆ** ដែលប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ១៧៥ ចុះថ្ងៃទី១៩ ខែសីហាឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍លើសេចក្តីសម្រេចទាំងមូល។

-តាមពាក្យបណ្តឹង ចុះថ្ងៃទី២៤-១២-៩៤ របស់ឈ្មោះ **សឆ** ប្តឹងពីចោរប្លន់ម៉ូតូរបស់ខ្លួនកាលពីថ្ងៃទី២៣-១២-៩៤វេលាម៉ោង២១ និង៣០ នាទីនៅម៉ុំមុខឪយ៉ាម៉ង់ បង្កឡើងដោយជន៣នាក់បានប្លន់យកម៉ូតូខ្លួន ខ្លួនរត់ចេញពីម៉ូតូបន្តិចក៏បាញ់តបវិញ ប៉ុន្តែបែរជាបាញ់ត្រូវម្នាក់ផ្សេងដែលជននោះមិនបានយកម៉ូតខ្លួនឡើយ។

-តាមកំណត់ហេតុយកចម្លើយ ចុះថ្ងៃទី០៦-០១-៩៥ របស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ **គជរវ** នៅតុលាការ ក្រុងភ្នំពេញបានឆ្លើយថា នៅថ្ងៃទី២៣-១២-៩៤ វេលាម៉ោងប្រហែលជាង២០ ឈ្មោះ **តគច** និង **យបរ** បានមកលេងផ្ទះខ្លួន លុះដល់ម៉ោងជាង២១ ពួកគេត្រឡប់ទៅផ្ទះរបស់គេវិញ បានប្រហែលកន្លះម៉ោងក្រោយមក ខ្លួនបានទទួលដំណឹងថាឈ្មោះ **យបរ** ត្រូវរបួសដោយគេបាញ់សម្រាកនៅមន្ទីរពេទ្យកាលម៉ែត។ ខ្លួនទាមទារជំងឺចិត្តពីជនល្មើសចំនួន២ម៉ឺនដុល្លា។

-បានឃើញសេចក្ដីសន្និដ្ឋាន របស់តំណាងអយ្យការអមតុលាការក្រុងភ្នំពេញថា៖

-មានមូលដ្ឋានចោទប្រកាន់លើឈ្មោះ **សឆ** ពីបទធ្វើមនុស្សឃាតដោយចេតនាតាមមាត្រា៣២ ច្បាប់ព្រហ្មទណ្ឌអន្តរកាល។

-គ្មានមូលដ្ឋានចោទប្រកាន់លើឈ្មោះ **កលហ** និង **តគច** ពីបង្ករបួសស្នាមលើអ្នកដទៃ គប្បីលើកលែងការចោទប្រកាន់។

-ជូនរឿងទៅតុលាការវិនិច្ឆ័យតាមច្បាប់។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ២២(គ) ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩៩៥ របស់តុលាការក្រុងភ្នំពេញ ដែលបានសម្រេច៖

១-ឱ្យឈ្មោះ **សឆ** រួចខ្លួនពីការចោទប្រកាន់ពីបទធ្វើមនុស្សឃាតដោយចេតនា ប្រព្រឹត្តិនៅក្រុងភ្នំពេញកាលពី ថ្ងៃទី២៣-១២-៩៤។

២-ដោះលែងជាបន្ទាន់ឈ្មោះ **សឆ** ប្រសិនបើឈ្មោះនេះមិនត្រូវបានឃុំខ្លួនពីបទល្មើសផ្សេងទៀតទេ។

៣-សម្ភារដកហូតមាន:

-អាវុធម៉ាកកា៥៩ លេខ៨៤០៨ បង់មួយគ្មានគ្រាប់

-លិខិតអនុញ្ញាតឱ្យប្រើប្រាស់អាវុធលេខ០១០១៣៧មួយ ។

-ម៉ូតូគុបជ្រុងអាគុយស្នួតពណ៌ទឹកប៊ិចលេខតួសេ៥០,៩៦៨៨១៥៥ លេខម៉ាស៊ីនសេ៥០អឺ៩៦៨៨១៨៨មួយគ្រឿងត្រូវប្រគល់ឱ្យ **សឆ**វិញ។

-ដំបងមូលមួយពណ៌ឈាមជ្រូកប្រវែង០,៥មត្រូវរឹបអូសនិងបំផ្លាញចោល។

៤-សាលក្រមនេះប្រកាសជាសាធារណៈ ចំពោះមុខគូក្តីសម្រេចបើកផ្លូវឧទ្ធរណ៍រយៈពេល២ខែគិតចាប់ពីថ្ងៃនេះតទៅ។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ១៦(គ) ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ ១៩៩៥ របស់លោក **គជរ** ដែលប្តឹងតវ៉ាពីសាលក្រមព្រហ្មទណ្ឌលេខ២២(គ) ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩៩៤ របស់តុលាការក្រុងភ្នំពេញ លើសេចក្តីសម្រេចទាំងមូល។

-បានឃើញសេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ថា៖

១-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី៣-៥-៩៥ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ **គជរ** ជាត្រឹមត្រូវ តាមទម្រង់និងគតិច្បាប់។

២-បដិសេធសាលក្រមព្រហ្មទណ្ឌលេខ២២(គ)ចុះថ្ងៃទី២៨-៤-៩៥ របស់តុលាការក្រុងភ្នំពេញ ចោលជាអសាបង់។

៣-ចោទប្រកាន់ឈ្មោះ **សឆ** ពីបទៈធ្វើមនុស្សឃាតដោយចេតនា ប្រព្រឹត្តិនៅក្រុងភ្នំពេញកាលពីថ្ងៃទី២៣-១២-៩៤ តាមបញ្ញត្តិមាត្រា៣២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

-បានឃើញសាលដីកាកំបាំងមុខព្រហ្មទណ្ឌលេខ១៥៦ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ១៩៩៦ របស់សាលាឧទ្ធរណ៍ដែលបានសម្រេច៖

១-ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី៣-៥-៩៥ របស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ **គជរ** ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។

២-បដិសេធសាលក្រមព្រហ្មទណ្ឌលេខ២២(គ) ចុះថ្ងៃទី២៨-៤-៩៥ របស់តុលាការក្រុងភ្នំពេញចោលជាអសារបង់។

៣-ផ្ដន្ទាទោសឈ្មោះ **សឆ** ដាក់ពន្ធនាគារកំណត់៨ឆ្នាំ គិតចាប់ពីថ្ងៃចាប់ខ្លួនលើកទី២ ដោយដករយៈពេលឃុំខ្លួន លើកទី១ ចំនួន៥៦ ថ្ងៃចេញពីបទៈ ធ្វើមនុស្សឃាតដោយចេតនាមានអាវុធតាមបញ្ញត្តិមាត្រា៣២,២៨ ច្បាប់ព្រហ្មទណ្ឌអន្តរកាល។

៤- បង្គាប់ឱ្យឈ្មោះ **សឆ** សងប្រាក់សំណងរដ្ឋប្បវេណីចំនួន៥០០០ ដុល្លា ទៅដើមបណ្ដឹងរដ្ឋប្បវេណីសំណូមពរលើសពីនេះបដិសេធចោល។ ក្នុងករណីទណ្ឌិតគ្មានប្រាក់សងធនទណ្ឌទេ បង្គាប់ឱ្យដាក់គុកដល់រូបកាយ តាមមាត្រា៧ ច្បាប់ស្ដីពីការដាក់គុកបង្ខំដល់រូបកាយក្នុងរឿងព្រហ្មទណ្ឌ។

៥-សម្ភារដកហូតមាន៖

-អាវុធម៉ាកកា៥៩ រលេខ៨៤០៨ បង់មួយគ្មានគ្រាប់ត្រូវរឹបអូសនិង ប្រគល់ឱ្យអង្គភាពនគរបាលចរាចរជើងគោក។

-ម៉ូតូម៉ាកគុបជ្រុងអាគុយស្ទួតពណ៌ទឹកប៊ិចលេខតួសេ៥០៩៦៨៨១៥៥ លេខម៉ាស៊ីនសេ៥០អី៩៦៨៨១១៨ មួយគ្រឿងត្រូវឃាត់ទុកដើម្បីធានាសំណងរដ្ឋប្បវេណី ។

-ដំបងមូលពណ៌ឈាមជ្រូកប្រវែង០,៥ម ត្រូវរឹបអូស និងបំផ្លាញចោល។

៦-សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណៈចំពោះមុខមេធាវី ជនជាប់ចោទដើមបណ្តឹរដ្ឋប្បវេណី និងមេធាវីការពារឱ្យដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទសម្រេចបើកផ្លូវប្តឹងទាស់សាទុក្ខក្នុងកំណត់ច្បាប់។

-បានឃើញបណ្តឹងទាស់លេខ៣៧ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩៦ របស់ឈ្មោះ **សរ** ដែលប្តឹងតវ៉ាពីសាលដីកាកំបាំងមុខ ព្រហ្មទណ្ឌលេខ១៥៦ ចុះថ្ងៃ២៩ ខែមិថុនា ឆ្នាំ១៩៩៦ របស់សាលាឧទ្ធរណ៍ លើសេចក្តីសម្រេចទាំងមូល។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ១៧៥ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ ១៩៩៧ របស់សាលាឧទ្ធរណ៍ដែលបានសម្រេច៖

១-ទទួលពាក្យបណ្តឹងទាស់ ចុះថ្ងៃទី២៥-១០-៩៦ របស់ជនជាប់ចោទ ឈ្មោះ **សរ** ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែលើកចោលចោដោយទាស់ខុស នឹងគតិច្បាប់។

២-តម្កល់សាលដីកាកំបាំងមុខលេខ១៥៦ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ ១៩៩៦ របស់សាលាឧទ្ធរណ៍ទុកជាបានការ ប៉ុន្តែលើកលែងចំណុចទី៣ ដែលត្រូវកែប្រែជា៖

-ផ្តន្ទាទោសឈ្មោះ **សរ** ដាក់ពន្ធនាគារ កំណត់៣ឆ្នាំចាប់គិតពីថ្ងៃចាប់ខ្លួនបានលើកទី២ ដោយដករយៈពេលឃុំខ្លួនលើកទី១ ចំនួន៥៦ថ្ងៃចេញ ពីបទៈធ្វើមនុស្សឃាត ដោយចេតនាមានអាវុធ ប្រព្រឹត្តិនៅក្រុងភ្នំពេញកាលពីថ្ងៃទី ២៣-១២-៩៤បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងឱ្យផ្តន្ទាទោសតាមបញ្ញត្តិ មាត្រា៣២,៦៨នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

៣-សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណៈចំពោះមុខមេធាវី ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីជនជាប់ចោទ ប៉ុន្តែចាត់ទុកជាចំពោះមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណីសម្រេចបើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់។

-បានឃើញបណ្តឹងសាទុក្ខលេខ៣៤៥ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៩៧ របស់ឈ្មោះ **សឆ** ដែលប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ១៧៥ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍ លើសេចក្តីសម្រេចទាំងមូល។

-បានឃើញសារណា ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ១៩៩៨ របស់ឈ្មោះ **សឆ** ជាម្ចាស់បណ្តឹងសាទុក្ខធ្វើឡើងក្នុងកំណត់ច្បាប់។

-បានឃើញសារណា ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៨ របស់លោក**គ ជរវ** ជាចុងបណ្តឹងសាទុក្ខ ធ្វើឡើងក្នុងកំណត់ច្បាប់។

-បានស្តាប់អំណានសាវតាជាតិរបស់ជនជាប់ចោទឈ្មោះ **សឆ** ម្ចាស់បណ្តឹងសាទុក្ខនៅពេលជំនុំជម្រះ។

-បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូលថា៖ សាលដីកាលេខ១៧៥ ចុះថ្ងៃទី ២៩-៨-៩៧ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះគឺ ត្រឹមត្រូវតាមទម្រង់ នឹងគតិច្បាប់ហើយ ម្យ៉ាងទៀតដើមបណ្តឹរដ្ឋប្បវេណីយល់ព្រមចំពោះទណ្ឌកម្ម ដែលសាលាឧទ្ធរណ៍បានបន្ថយពីដាក់គុក៨ឆ្នាំ មក៣ឆ្នាំវិញផងដែរ។ ហេតុនេះសូមក្រុមប្រឹក្សាជំនុំជម្រះពិនិត្យ និងសម្រេច។

-បានស្តាប់អំណានសារណារបស់ឈ្មោះ **សឆ** ជាម្ចាស់បណ្តឹងសាទុក្ខនៅពេលជំនុំជម្រះ។

-បានស្តាប់ចម្លើយអះអាងរបស់លោក **គជរវ** ជាចុងបណ្តឹងសាទុក្ខ នៅពេលជំនុំជម្រះថា សារណារបស់ជនជាប់ចោទគ្រាន់ជាពាក្យដោះសា ហើយក៏ពុំមែនបាញ់ទៅលើជនរងគ្រោះជាការការពារស្របច្បាប់ដែរ។ ម្យ៉ាងទៀតជនរងគ្រោះគ្មានអាវុធដើម្បីតបតទៅជនជាប់ចោទឡើយ។ ដូច្នេះអំពើជនជាប់ចោទពិតជាមានចេតនាសម្លាប់ជនរងគ្រោះប្រាកដមែន។ សូមតុលាការសម្រេចតាមច្បាប់និងប្តឹងទាមទារជំងឺចិត្តចំនួន៥០០០ដុល្លា។

-បានស្តាប់សេចក្តីសន្និដ្ឋានការពារ របស់លោក...ជាមេធាវីការពារជនជាប់ចោទឈ្មោះ **សរឆ** នៅពេលជំនុំជម្រះថា៖ កូនក្តីរបស់ខ្ញុំពិតជាការពារស្របច្បាប់មែន ប៉ុន្តែគ្រាន់តែច្បាប់ពុំបានចែង ។ដូច្នេះសូមតុលាការកំពូលបង្កើតជាយុទ្ធសាស្ត្រ និងលើកលែងចោទប្រកាន់កូនក្តីខ្លួនដោយអនុគ្រោះ។

-បានស្តាប់សេចក្តីសន្និដ្ឋាន បន្ថែមនាពេលសវនាការ របស់តំណាងមហាអយ្យការអមតុលាការកំពូលថា៖ អំពើជនជាប់ចោទគឺមានចេតនាសម្លាប់មនុស្សពេញទីហួសព្រំដែនការពារខ្លួនស្របច្បាប់ ព្រោះជនរងគ្រោះពុំមានអ្វីតទល់ទេ ។ សូមតុលាការសម្រេចតាមច្បាប់ ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីស្តាប់សារណារបស់ជនជាប់ចោទចម្លើយ របស់ដើមបណ្តឹងរដ្ឋប្បវេណី និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីជនជាប់ចោទ។

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថាបណ្តឹងសាទុក្ខលេខ៣៤៥ ចុះថ្ងៃទី១៥-៩-៩៧ របស់ឈ្មោះ **សរឆ** ប្តឹងពីសាលដីកាព្រហ្មទណ្ឌ លេខ១៧៥ ចុះថ្ងៃទី២៩-៨-៩៧ របស់

សាលាឧទ្ធរណ៍លើសេចក្តីសម្រេចទាំងមូល ធ្វើឡើងក្នុងកំណត់ច្បាប់តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំងនិងសកម្មភាពរបស់សាលាជម្រះក្តី។

-យល់ឃើញថា មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថាឈ្មោះ **សរ** ពិតជាបានប្រព្រឹត្តិអំពើមនុស្សឃាតដោយចេតនា កាលពីថ្ងៃទី២៣-១២-៩៤ វេលាម៉ោង២២ និង៤០នាទីតាមមហាវិថីព្រះមុនីវង្សមុំសណ្ឋាគារឌីយ៉ាម៉ង់ប្រាកដមែន។ បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និងផ្តន្ទាទោសតាមមាត្រា៣២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

-យល់ឃើញថាការលើកឡើងរបស់ជនជាប់ចោទក្នុងសារណាការពាររបស់ខ្លួនថាការបាញ់សម្លាប់ជនរងគ្រោះ គឺជាការការពារខ្លួនស្របច្បាប់នោះ នោះជាការភាន់ច្រឡំពីព្រោះជនរងគ្រោះមានតែដំបងខ្លីតូចមួយ រួចជនជាប់ចោទប្រើកាំភ្លើង បាញ់ទៅលើជនរងគ្រោះចំនួន៣គ្រាប់។

-យល់ឃើញថាក្នុងសារណា ឆ្លើយតបចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ១៩៩៨ ដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើង ឯកភាពចំពោះទោសគុក ដែលសាលាឧទ្ធរណ៍ផ្តន្ទាទោសជនជាប់ចោទហើយ។

-យល់ឃើញថាជនជាប់ចោទបានធ្វើសារណាជូនមកតុលាការកំពូល និងបានទទួលដីកាកោះហើយ ប៉ុន្តែពុំបាន ចូលរួមនាពេលសវនាការនេះទេដូច្នេះតុលាការកំពូលជំនុំជម្រះ រឿងនេះកំបាំងមុខជនជាប់ចោទ ប៉ុន្តែចាត់ទុកជាចំពោះមុខ។

-យល់ឃើញថាសាលដីកាព្រហ្មទណ្ឌលេខ១៧៥ ចុះថ្ងៃទី២៩-៨-៩៧ របស់សាលាឧទ្ធរណ៍ ដែលសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវទាំងទម្រង់ទាំងគតិច្បាប់។

## ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តីចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទ ប៉ុន្តែចាត់ទុកជាចំពោះមុខ

១-ទទួលបណ្តឹងសាទុក្ខលេខ៣៤៥ ចុះថ្ងៃទី១៥-៩-៩៧ របស់ឈ្មោះ **សរ** ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ១៧៥ ចុះថ្ងៃទី២៩-៨- ៩៧ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល។

៣-សាលដីកានេះប្រកាសសវនាការជាសាធារណៈនៅថ្ងៃទី១៧ខែមីនាឆ្នាំ១៩៩៩។